នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Sep-2014, 16:01
CMS/CFO: Sann Rada

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជតក
**ដាក់ទៅ** : អង្គជំនុំជម្រះតុលាការកំពូល
**ថ្ងៃដាក់** : ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញា
**ភាសាដើម** : អង់គ្លេស

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីររបស់មេធាវីការពារក្ដី នួន ជា សុំឲ្យទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែម ទាក់ទងនឹងបណ្ដឹងសាធុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០១

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រ៊ីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Anta GUISSÉ
លោក Arthur VERCKEN

## I. សេចក្តីផ្តើម

១- អនុលោមតាមវិធាន១០៨(៧) សហព្រះរាជអាជ្ញាធ្វើការឆ្លើយតបទៅនឹងសំណើពីរដែលបានដាក់ដោយមេធាវីការពារក្តី នួន ជា[1] និងដែលបានចូលរួមដោយមេធាវីការពារក្តី ខៀវ សំផន[2] (ចាប់ពីនេះតទៅ សំណើទាំងពីររួមគ្នាហៅថា "សំណើ") ដែលបានស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយក និងពិចារណាលើភស្តុតាងបន្ថែម ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើនេះគឺឆាប់ពេក និងមានវិការៈខាងនីតិវិធី។ បច្ចុប្បន្ននេះ បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម០០២/០១ មិនទាន់បានដាក់នៅឡើយ។ ដូច្នេះ អង្គជំនុំជម្រះនេះក៏មិនទាន់មានគេប្តឹងមកខ្លួន អនុលោមតាមវិធាន១០៨(១)នៅឡើយដែរ។ ជាងនេះទៀត សហព្រះរាជអាជ្ញាមិនអាចលើកឡើងឱ្យបានគ្រប់គ្រាន់ភាពពាក់ព័ន្ធនៃភស្តុតាងដែលបានស្នើក្នុងសំណើនេះ រហូតដល់ការជូនដំណឹងបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខត្រូវបានដាក់ដោយមេធាវីការពារក្តីសិន ដែលនឹងកំណត់ពីវិសាលភាពនៃបណ្តឹងសាទុក្ខ និងបញ្ជាក់ពីបញ្ហាភស្តុតាងពាក់ព័ន្ធដែលបានស្នើសុំ។ សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះកំណត់ពេល ឬផ្តល់ការណែនាំមួយអំពីការដាក់សំណើតាមវិធាន១០៨(៧) និងផ្តល់ការអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបពេញលេញទៅនឹងសំណើទាំងនោះ បន្ទាប់ពីមេធាវីការពារក្តីបានដាក់ការជូនដំណឹងសាទុក្ខ និងសារណាសាទុក្ខរបស់ពួកគេ។ ចុងក្រោយ សហព្រះរាជអាជ្ញាសង្កេតឃើញថា *គ្រាន់តែមួយក្រឡេកភ្នែក* គឺសំណើខកខានមិនបានបង្ហាញឱ្យឃើញថា មេធាវីការពារក្តីមានភស្តុតាងថ្មីដែលនឹងបន្ថយតម្លៃនៃការរកឃើញអង្គហេតុ ឬអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ គ្មានសំណើណាមួយបានបំពេញលក្ខខណ្ឌតម្រូវនៃវិធាន១០៨(៧)ទេ ដែលតម្រូវថា ការទទួលយកភស្តុតាងថ្មីអនុញ្ញាតបានតែក្នុងករណីមាន "កត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេច" នៅក្នុងសេចក្តីសម្រេចនោះតែប៉ុណ្ណោះ។

## II. ចម្លើយតប

### ក. សំណើរបស់មេធាវីការពារក្តីគឺឆាប់ពេក ដោយសារបណ្តឹងសាទុក្ខមិនទាន់បានដាក់នៅឡើយ

[1] **F2** សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០១, ១ កញ្ញា ២០១៤។ **F2/1** សំណើទីពីរស្នើសុំឱ្យពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០១, ២ កញ្ញា ២០១៤។

[2] **F2/1/1** Soutien de la Défense de M. Khieu Samphan aux Deux Premières Requêtes de la Défense de M. Nuon Chea aux fins d'Admission et d'Examen de Moyens de Preuve Supplémentaires en Appel, ៨ កញ្ញា ២០១៤។

២- ខណៈចំណាងជើងសំណើសុំ ត្រូវបានធ្វើឡើង "ដោយជាប់ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសវនាការក្នុងសំណុំរឿង០០២/០១" បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនោះ មិនទាន់បានដាក់នៅឡើយ។ វិធាន១០៨ ចែងពីនីតិវិធីសម្រាប់ប្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល និងចែងថា សំណុំរឿងត្រូវបញ្ជូនទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះនេះ "នៅក្នុងករណីមានបណ្តឹងសាទុក្ខចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង"[3]។ វិធាន១០៥(៣) ចែងថា៖

"ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលមានបញ្ជាក់ពីមូលដ្ឋាននីមួយៗ ត្រូវបញ្ជាក់ពីកំហុសអង្គច្បាប់ដែលនាំឱ្យសេចក្តីសម្រេចនោះមោឃៈ និងកំហុសអង្គហេតុ ដែលនាំឱ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ បន្ទាប់មក ម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់សារណាបណ្តឹងសាទុក្ខដោយមានបញ្ជាក់ពីអំណះអំណាង និងឯកសារសម្អាងដែលគាំទ្រមូលដ្ឋាននីមួយៗ..."។

៣- វិធាន១០៨(៧)នេះផ្ទាល់ ក៏មានគូសបញ្ជាក់ពីតម្រូវការសម្រាប់បណ្តឹងសាទុក្ខដែលត្រូវដាក់ផងដែរ ដោយដាក់លក្ខខណ្ឌថា សំណើ "ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងដោយផ្ទាល់រវាងភ័ស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសម្អាងហេតុជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក" និងថាភ័ស្តុតាងបន្ថែមដែលបានស្នើសុំទាំងនោះ "អាចជាកត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ"។

៤- អង្គជំនុំជម្រះតុលាការកំពូលនៅពេលនេះ មិនទាន់បានទទួលបណ្តឹងសាទុក្ខណាមួយនៅឡើយប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០១។ នៅពេលមានការជូនដំណឹងពីការប្តឹងសាទុក្ខ គ្មាន "កំហុសអង្គច្បាប់" ឬ"កំហុសអង្គហេតុ" ដូចដែលបានចោទប្រកាន់ អាចបញ្ជាក់អំពីទំនាក់ទំនងទៅនឹងភ័ស្តុតាងថ្មីនោះទេ ហើយរហូតដល់មេធាវីការពារក្តីបានដាក់សារណាបណ្តឹងសាទុក្ខដែលមានបញ្ជាក់មូលហេតុពេញលេញនោះសិន គេមិនអាចវាយតម្លៃឱ្យបានពេញលេញពីរបៀប និងថាតើភ័ស្តុតាងថ្មីទាំងនោះនឹងធ្វើឱ្យប៉ះពាល់ដល់ការរកឃើញ ឬសេចក្តីសម្រេចដែលគេបានប្តឹង

[3] វិធាន១០៨(១) នៃវិធានផ្ទៃក្នុង។

សាទុក្ខនោះឡើយ។ បើដូច្នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើគឺឆាប់ពេក និងគួរត្រូវច្រានចោលដោយអង្គជំនុំជម្រះនេះ។

៥- មេធាវីការពារក្តី នួន ជា ខ្លួនឯង ទទួលស្គាល់អំពីលក្ខណៈឆាប់ពេកនៃការដាក់ឯកសារនេះដែរ។ ពួកគាត់រៀបរាប់ពីការដាក់សារណានេះថា ជាសារណាមួយដែលបង្ហាញ "អំណះអំណាងខ្លី" និងអះអាងថាមេធាវីការពារក្តីនឹងអាច"បង្ហាញឲ្យឃើញពេញលេញពីសារៈសំខាន់"នៃភ័ស្តុតាងបន្ថែមដែលស្នើឡើង "គ្រាន់តែជាផ្នែកនៃបណ្តឹងសាទុក្ខរបស់ខ្លួនចំពោះសាលក្រមចុងក្រោយប៉ុណ្ណោះ"[4]។

## ខ. សេចក្តីសង្កេតបឋមលើអង្គសេចក្តីនៃសំណើរបស់មេធាវីការពារក្តីសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម

*បទសម្ភាសន៍របស់ ថេត សម្បត្តិ (Thet Sambath) ជាមួយវិទ្យុសម្លេងអាមេរិកកាំង (Voice of America)*

៦- ទាក់ទងនឹងសំណើសុំឲ្យទទួលយក *បទសម្ភាសន៍របស់* Thet Sambath *ជាមួយ* Voice of *America* ធ្វើឡើងក្នុងខែសីហា ឆ្នាំ២០១៤នោះ សហព្រះរាជអាជ្ញាសង្កេតឃើញថាមេធាវីការពារក្តីពឹងផ្អែកលើមតិផ្ទាល់ខ្លួនដែល លោក សម្បត្តិ បានផ្តល់ឲ្យទាក់ទងនឹងពិរុទ្ធភាពដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញលើ នួន ជា និង ខៀវ សំផន ដែលមិនអាចជឿទុកចិត្តបាន និងមិនអាចទទួលយកបានដែរ។ មតិរបស់លោក សម្បត្តិ ដែលមិនមានបង្ហាញភស្តុតាងមិនអាចពិចារណាថាជា "កត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេច" ដែលអាចធ្វើឲ្យផ្លាស់ប្តូរដល់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[5]។ ក្នុងសម្ភាសន៍នេះ ថេត សម្បត្តិ បានផ្តល់ការសន្និដ្ឋានផ្ទាល់ខ្លួនដោយផ្អែកលើការស្រាវជ្រាវដែលគាត់បានធ្វើ - ឧ.ថា "ខៀវ សំផន មិនមានអំណាចទេ" ដោយសារ "អ្វីៗត្រូវបានសម្រេចដោយ ប៉ុល ពត និង នួន ជា"[6] និងថា "នួន ជា ត្រូវបានកាត់ទោសខុសចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ ដោយសារគាត់មិនមែនជាអ្នកបញ្ជា

---

[4] **F2** សំណើសុំឲ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០១, ១ កញ្ញា ២០១៤, កថាខណ្ឌទី១៣។ **F2/1** សំណើទីពីរស្នើសុំឲ្យពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០១, ២ កញ្ញា ២០១៤, កថាខណ្ឌទី១៣។

[5] *សូមមើល* វិធាន១០៨(៧) នៃវិធានផ្ទៃក្នុង ("ភាគីអាចស្នើសុំបន្ថែមភ័ស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន៨៧(៣) បើសិនជាភ័ស្តុតាងនោះ មិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ")។

[6] **F2** សំណើសុំឲ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០១, ១ កញ្ញា ២០១៤, ទំព័រ៤។

ឱ្យសម្លាប់ទាហាន លន់ នល់ នៅទីតាំងនោះទេ[7]។ លោក សម្បត្តិ មិនបានផ្ដល់ព័ត៌មានលម្អិតទេ ទាក់ទងនឹងប្រភពភស្តុតាងរបស់គាត់ ឬមិនមានចេតនាផ្ដល់នូវបទសម្ភាសន៍ និងភស្តុតាងដែលជាដើមចង ដែលគំនិតរបស់គាត់បានផ្អែកលើ។

៧- មេធាវីការពារក្ដីបង្ហាញខុសនៅក្នុងសំណើរបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងមិនខិតខំប្រឹងប្រែងក្នុងការទទួលយកភស្តុតាងរបស់ ថេត សម្បត្តិ ទេ។ តាមពិត លោក សម្បត្តិ និងអ្នកផលិតរបស់គាត់ឈ្មោះ Rob Lemkin តែងតែបដិសេធម្ដងហើយម្ដងទៀត ពុំព្រមសហការជាមួយតុលាការ និងពុំព្រមផ្ដល់ភស្តុតាងដល់តុលាការដែរ[8]។ ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង០០២ ក្នុងការឆ្លើយតបមួយទៅនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដែលបានដាក់ដោយសហព្រះរាជអាជ្ញា[9] សហចៅក្រមស៊ើបអង្កេតបានសរសេរទៅលោក Lemkin ដោយស្នើសុំបទសម្ភាសន៍របស់ នួន ជា មួយច្បាប់ដែលមាននៅក្នុងខ្សែភាពយន្ត *សត្រូវរបស់ប្រជាជន (Enemies of the People)*[10]។ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយ ថេត សម្បត្តិ លោក Lemkin បានឆ្លើយថា ពួកគាត់មិនចង់ផ្ដល់ឱ្យតុលាការទេ ដោយសារខ្សែភាពយន្តនេះមិនទាន់បាន "ផ្សព្វផ្សាយជាទូទៅ"[11] នៅឡើយ។ Messr. Lemkin និង សម្បត្តិ ខកខានមិនបានផ្ដល់ទាំងខ្សែភាពយន្ត និងខ្សែវីឌីអូនៃបទសម្ភាសន៍ មកតុលាការនៅក្រោយថ្ងៃផ្សព្វផ្សាយ ហើយសហព្រះ

[7] *ដដែលដូចខាងលើ*, ត្រង់ទំព័រ៥។

[8] **D344/1** ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងខ្សែភាពយន្ត "សត្រូវរបស់ប្រជាជន" (*Enemies of the People*), ៩ មេសា ២០១០, កថាខណ្ឌទី៨ ("សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ជារឿងគួរឱ្យសោកស្ដាយណាស់ដែលថា... ក៏អ្នកផលិតខ្សែភាពយន្តរូបនេះបានបង្ហាញនូវអាកប្បកិរិយាមិនចង់សហការសោះ គឺបន្ទាប់ពីតុលាការបានព្យាយាមធ្វើការទាក់ទងជាផ្លូវការក៏ដោយ និងទោះបីជាតុលាការផ្ដល់នូវការធានាតាមផ្លូវច្បាប់លើឯកសិទ្ធិភាពមួយចំនួនទៀត [ភាពសម្ងាត់] ក៏ដោយ")។ **E294/1** សេចក្ដីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី, ឱ្យចាប់ផ្ដើមការស៊ើបអង្កេត និងឱ្យកោះហៅលោក ROB LEMKIN, ២៤ កក្កដា ២០១៣, កថាខណ្ឌទី១៦ និងកំណត់សំគាល់ជើងទំព័រលេខ ៣១ ("តវិយាបថរបស់លោក Lemkin នៅក្នុងដំណាក់កាលមុនការជំនុំជម្រះបង្ហាញយ៉ាងច្បាស់លាស់នូវកង្វះនៃការផ្ដល់កិច្ចសហការ។ ទាំងរូបគាត់ ទាំងលោក សម្បត្តិ បានបញ្ជាក់... អំពីហេតុផលមួយចំនួនដែលគាំទ្រដល់ការបដិសេធរបស់គាត់ ក្នុងការប្រគល់សម្ភារៈពាក់ព័ន្ធឱ្យដល់ អ.វ.ត.ក... អង្គជំនុំជម្រះមិនមានការជឿជាក់លើតម្លៃនៃការកោះហៅសាក្សីដែល *តាមហេតុការណ៍ពិត* បានបង្ហាញជានិច្ចនូវភាពស្ទាក់ស្ទើរក្នុងការជួយដល់តុលាការ")។

[9] **D344** សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងបទសម្ភាសន៍ជាមួយ នួន ជា និងខ្សែភាពយន្តឯកសាររឿង "សត្រូវរបស់ប្រជាជន" (*Enemies of the People*), ៣ កុម្ភៈ ២០១០។

[10] **D344/1.1** លិខិតពីចៅក្រម យូ ប៊ុនឡេង និង Marcel Lemonde ជូន Robert Lemkin, ៣ កុម្ភៈ ២០១០។

[11] **D344/1.2** អ៊ីម៉ែលពី Rob Lemkin ជូន Marcel Lemonde ជូន Robert Lemkin, ៩ កុម្ភៈ ២០១០។

រាជអាជ្ញាត្រូវទិញ DVD នោះ ដែលជាខ្សែអាត់សម្លេងរបស់ នួន ជា ដែលជាកំណត់ហេតុដាក់បន្ទុកដ៏ខ្លាំងមួយ សម្រាប់ដាក់បញ្ចូលទៅក្នុងសំណុំរឿង និងដើម្បីទទួលយកជាភ័ស្តុតាង[12]។

៨- នៅក្នុងសវនាការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១ ទាំងសហព្រះរាជអាជ្ញា និងទាំងមេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យលោក ថេត សម្បត្តិ ចូលមកបង្ហាញខ្លួនក្នុងនាមជាសាក្សីនៅក្នុងពេលសវនាការ[13] ក៏ប៉ុន្តែលោក សម្បត្តិ ជៀសផុតពីការខំប្រឹងទាក់ទងរបស់តុលាការជាមួយគាត់ ហើយបានស្ថិតនៅសហរដ្ឋអាមេរិក ដែលស្ថិតនៅក្រៅវង្វង់យុត្តាធិការនៃដីកាកោះរបស់តុលាការ[14]។ គាត់ថែមទាំងខកខានក្នុងការឆ្លើយតបទៅនឹងសំណើសុំឱ្យផ្តល់ព័ត៌មាន ពីអង្គភាពគាំពារសាក្សី(“WESU”) សម្រាប់ទាក់ទងជាមួយពួកយោធាខ្មែរក្រហមដែលបានចូលរួម នៅក្នុងការសម្លាប់នៅទទួលពោធិ៍ជ្រៃ ហើយការធ្វើសម្ភាសន៍ពួកគេមានដាក់បញ្ចូលនៅក្នុងខ្សែភាពយន្តរបស់លោក សម្បត្តិ ក្រោមចំណងជើងថា៖ *មួយថ្ងៃនៅឯពោធិ៍ជ្រៃ (One Day at Po Chrey)*[15]។ ហេតុដូចនេះ គឺជាការលាក់ពុតរបស់លោក ថេត សម្បត្តិ ដែលទិទៀនចំពោះតុលាការក្នុងការខកខានមិនបានធ្វើការស្តាប់ចម្លើយពួកអតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនដែលលោក សម្បត្តិ បានបញ្ជាក់ប្រាប់ពីទីកន្លែងរស់នៅ(របស់ពួកគេ) និងថា គាត់បានទទួចំពោះ អវតក “ឱ្យចេញដីកាកោះហៅអ្នកណាក៏ដោយមិនគិតថាមានតួនាទីអ្វីក៏ដោយឱ្យមកកាន់តុលាការ ហើយចាត់ការតាមនោះទៅ”[16]។ លោក សម្បត្តិ គួរតែគោរពតាមពាក្យសំដីរបស់ខ្លួន ហើយគួរតែធ្វើឱ្យខ្លួនគាត់ផ្ទាល់ និងខ្សែអាត់ពីការធ្វើសម្ភាសន៍របស់គាត់ មានចំពោះអង្គជំនុំជម្រះសាលាដំបូង នៅក្នុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីក្នុងសំណុំរឿងលេខ០០២។

---

[12] **E186** ការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ស្តីពីខ្សែភាពយន្តឯកសារដែលមានចំណងជើងថា “សត្រូវរបស់ប្រជាជន” (*Enemies of the People*), ១៧ មេសា ២០១២។ **E294/1** សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី, ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក ROB LEMKIN, ២៤ កក្កដា ២០១៣, កំណត់សំគាល់ជើងទំព័រលេខ ៣១។

[13] ឯកសារលេខ **E9/4.3** ឧបសម្ព័ន្ធទី៣ ភ្ជាប់ជាមួយនឹងបញ្ជីអ្នកជំនាញ, សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០ (លេខ២១៥)។ ឯកសារលេខ **E9/4/4.4** ឧបសម្ព័ន្ធ ក: បញ្ជីឈ្មោះសាក្សីដែលបានស្នើឡើងរបស់ក្រុមមេធាវីការពារក្តី នួន ជា (លេខ ៤៥៦)។

[14] ឯកសារលេខ **E294/1** សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំអោយទទួលយកនូវឯកសារថ្មីៗ ដើម្បីផ្តួចផ្តើមគំនិតធ្វើការស៊ើបសួរ និងកោះហៅលោក Rob Lemkin, ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣, កថាខណ្ឌទី១៤។ ឯកសារ **E292/1/2** អនុស្សារណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលមានចំណងជើងថា៖ "សាក្សីនានាដែលមានសក្តានុពល-ដែលមិនអាចមានលទ្ធភាពកំណត់ទីកន្លែងរស់នៅរបស់ពួកគេបាន", ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៣។

[15] ឯកសារលេខ **E292/1/2** អនុស្សារណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលមានចំណងជើងថា "សាក្សីនានាដែលមានសក្តានុពលមិនអាចមានលទ្ធភាពកំណត់ទីតាំងបាន", ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៣។

[16] សំណើសុំផ្តល់ និងពិចារណាលើភស្តុតាងបន្ថែម ដែលជាប់ទាក់ទងជាមួយបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមជំនុំជម្រះក្តីក្នុងសំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤, ទំព័រ ៨។

៩- ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់ដោយត្រឹមត្រូវ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនកាលពីខែកក្កដា ឆ្នាំ២០១៣ ដោយច្រានចោលនូវសំណើរបស់សហមេធាវីរបស់ នួន ជា ដែលសុំឱ្យចេញដីកាកោះហៅឈ្មោះ Rob Lemkin ឱ្យមកធ្វើជាសាក្សីសម្រាប់ពេលសវនាការ។ "ប្រភពនៃឯកសារដែលប្រហែលកំពុងតែស្ថិតនៅក្នុងការកាន់កាប់របស់លោក Lemkin និងលោក ថេត សម្បត្តិ អាចជាជំនួយច្រើនជាងសក្ខីកម្មរបស់ពួកគាត់"[17]។ សហព្រះរាជអាជ្ញាលើកឡើងថា លុះត្រាតែ និងរហូតទាល់តែ ប្រភពនៃឯកសារជាមូលដ្ឋានសំខាន់ត្រូវបានធ្វើឱ្យមានស្រាប់សម្រាប់ឱ្យតុលាការអាចងាយរកបាននោះទើប មតិផ្សេងៗ និងការកំណត់អំពីចរិតលក្ខណៈនៃសារៈសំខាន់ខាងផ្នែកច្បាប់នៃឯកសារទាំងនេះដែលបានថ្លែងនៅក្នុងការធ្វើបទសម្ភាសន៍ រយៈតាមវិទ្យុសំឡេងសហរដ្ឋអាមេរិក កាលពីខែសីហា ឆ្នាំ២០១៤ របស់លោកសម្បត្តិ អាចនឹងត្រូវបានផ្តល់ស្លានទម្ងន់តិចតួច ឬគ្មានទាល់តែសោះ ដែលមិនគួរត្រូវបានទទួលយក តាមវិធាន១០៨(៧)នៃវិធានផ្ទៃក្នុងនោះឡើយ។

១០- សហព្រះរាជអាជ្ញាក៏បានធ្វើការកត់សំគាល់ផងដែរ អំពីគួរឱ្យជឿទុកចិត្ត និងភាពអាចទទួលយកបាននៃមតិរបស់លោក ថេត សម្បត្តិ ដែលសហមេធាវីការពារក្តីខកខានមិនបានបង្ហាញជូនអង្គជំនុំជម្រះនេះ អំពីទំនាក់ទំនងជិតដឹតនឹងគ្នារវាងលោក សម្បត្តិ និង នួន ជា។ ភាពជំនាញនៅក្នុងការស៊ើបអង្កេតរបស់ ថេត សម្បត្តិ គឺមិនបាច់មានការងឿងឆ្ងល់ទេ។ ក៏ប៉ុន្តែ នៅក្នុងករណីនេះ អ្នកសារពត៍មានដែលមិនលំអៀងដែលធ្វើការសិក្សាស្រាវជ្រាវអំពី នួន ជា និងខ្មែរក្រហម គឺរូបគាត់ឃ្លាតចាកឆ្ងាយពីភាពអព្យាក្រិត្យហើយ។ ភរិយារបស់ ថេត សម្បត្តិ គឺជាសាច់ញាតិរបស់ នួន ជា ដែល "តែងតែទៅសួរសុខទុក្ខ"ភរិយារបស់ នួន ជា ជាញឹកញយ[18]។ ក្រោយពី នួន ជា ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅ អវតក កាលពីក្នុងខែកញ្ញា ឆ្នាំ២០០៧ សហមេធាវីការពារក្តីរបស់ នួន ជាបានជួយ ថេត សម្បត្តិ ក្នុងការទទួលបានការអនុញ្ញាតចូលជួបជាមួយកូនក្តីរបស់ពួកគេនៅក្នុងមន្ទីរឃុំឃាំងរបស់ អវតក ដោយការដាក់ចម្លើយក្លែងបន្លំជូនតុលាការ ដែលបញ្ជាក់អត្តសញ្ញាណរបស់ ថេត សម្បត្តិថាជា "ក្មួយប្រុស" របស់កូនក្តីពួកគេ[19]។ នៅក្នុងសៀវភៅនេះ

---

[17] ឯកសារលេខ **E294/1** សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំសុំអោយទទួលយកភស្តុតាងថ្មី ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក Rob Lemkin, ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣, កថាខណ្ឌទី១៦។

[18] ឯកសារលេខ **E1/22.1** ប្រតិចារឹកនៃសវនាការការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១, នៅម៉ោង ១១.៤៧នាទី.៤៥វិនាទី [សក្ខីកម្មរបស់ នួន ជា]។

[19] ឯកសារលេខ **A43/6** សំណើសុំការអនុញ្ញាត្តិជាអចិន្ត្រៃយ៍ ដើម្បីអោយគ្រួសាររបស់ជនត្រូវចោទ នួន ជា ចូលជួបសួរសុខទុក្ខ, ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០០៧, កថាខណ្ឌទី ៨ (ដែលចុះនៅក្នុងបញ្ជី "លោក ថេត សម្បត្តិ, ជនជាតិខ្មែរ, អាយុ ៣៨ឆ្នាំ, ជាក្មួយប្រុស")។

ដែលមានចំណងជើងថា៖ "*នៅខាងក្រោយវាលពិឃាត* Behind the Killing Fields" ថេត សម្បត្តិ បានទទួលសារភាពថា បានទៅជួបសួរសុខទុក្ខ នួន ជា "ប៉ុន្មានដងដែរ នៅក្នុងពេលដែលគាត់កំពុងឋិតនៅក្នុងពន្ធនាគារ" ប៉ុន្តែបាននិយាយថា ឈ្មោះរបស់គាត់ត្រូវបានគូសលុបចេញពីក្នុងបញ្ជីអ្នកដែលគេបានអនុញ្ញាតឱ្យចូលជួបសួរសុខទុក្ខ នៅពេលដែលសមត្ថកិច្ចរបស់តុលាការ "បានរកឃើញថាតើលោកសម្បត្តិនេះមែនទែន គឺជានរណា"(គឺថា មិនមែនជាក្មួយប្រុសរបស់ជនជាប់ចោទទេ)[20]។ ក្រោយពីនោះមក នួន ជា "នៅតែប្រឹងរកវិធីបញ្ជូនសារ [និងសំបុត្រផ្សេងៗ]" ទៅឱ្យលោកសម្បត្តិតាមរយៈឈ្មោះ លី គឹមស៊ាង (Ly Kimseang) ភរិយារបស់ នួន ជា ដែលនិយាយថា គាត់នឹកសម្បត្តិ ហើយបារម្ភអំពីគាត់"[21]។

១១- នៅក្នុងពេលជំនុំជម្រះ នួន ជា បានសារភាពថា គាត់បានសរសេរសៀវភៅមួយ និយាយពីខ្លួនគាត់ ហើយបានឱ្យសៀវភៅនោះទៅ ថេត សម្បត្តិ ដោយស្នើឱ្យបោះពុម្ពផ្សាយសៀវភៅនោះនៅទីក្រុងញីវយ៉ក ព្រោះថានៅទីនោះវានឹង("មានតម្លៃជាង")ការដែលបោះពុម្ពផ្សាយនៅក្នុងប្រទេសកម្ពុជា[22]។ មកទល់នឹងពេលនេះ គេមិនដឹងថា តើមានការសម្របសម្រួលគ្នាផ្នែកហិរញ្ញវត្ថុយ៉ាងដូចម្ដេចខ្លះនោះទេ រវាងថេត សម្បត្តិ និង នួន ជា ទាក់អំពីការបោះពុម្ពផ្សាយនៃសៀវភៅនោះ -គឺថាតើពួកគេមានការទំនាក់ទំនងអាជីវកម្មណាមួយ ជាបន្ថែមពីលើការទំនាក់ទំនងគ្នាជាបុគ្គលថែមទៀតដែរ ឬទេ ដែលតាមរយៈនោះ នួន ជា (ឬគ្រួសាររបស់គាត់) មានបានទទួលនូវចំណែកណានៃលុយកាក់ដែលជាផលកម្រៃបានមកពីសៀវភៅនោះ និងពីខ្សែភាពយន្ត *សត្រូវរបស់ប្រជាជន* (*Enemies of the People)* ដែរ ឬអត់។ ហេតុដូចនេះ ទើបភស្តុតាងទាំងឡាយដែល ថេត សម្បត្តិ ទទួលបានពីជនជាប់ចោទ និងពីពួកកម្មាភិបាលខ្មែរក្រហមនានា អាចនឹងឱ្យទទួលយកបាន (ល្គឹកណាតែបទសម្ភាសន៍ទាំងនោះត្រូវបានបោះពុម្ពផ្សាយ ឬមួយក៏ធ្វើឱ្យមានស្រាប់ដែលអាចឱ្យតុលាការងាយរកបានតែប៉ុណ្ណោះ)។ លោក សម្បត្តិ មិនអាចចាត់ទុកថាសាក្សីជំនាញឯករាជ្យដែលយោបល់របស់គាត់ស្ដីពីតួនាទី និងការទទួលខុសត្រូវរបស់ នួន ជា អាចឱ្យជឿទុកចិត្តបាន ក្នុងការឈានទៅដល់ការចេញសាលក្រមនោះបានឡើយ[23]។

---

[20] ឯកសារលេខ **E3/4202** សៀវភៅនិពន្ធដោយ លោក ថេត សម្បត្តិ និងលោក Gina Chon ដែលមានចំណងជើងថា "នៅខាងក្រោយវាលពិឃាត" "Behind the Killing Fields," ទំព័រ ១៥៨ (លេខ ERN ជាភាសាអង់គ្លេស 00757558)។

[21] *ដូចគ្នានឹងខាងលើ។*

[22] ឯកសារលេខ **E1/22.1** ប្រតិចារឹកនៃសវនាការជំនុំជម្រះក្ដីលើសំណុំរឿងលេខ០០២/០១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១, នៅចាប់ពីម៉ោង១២ ០០នាទី០៤វិនាទី ដល់ម៉ោង១២ ០២នាទី ៤៨វិនាទី [សក្ខីកម្មរបស់ នួន ជា]។

[23] ក្រុមមេធាវីការពារក្ដីរបស់ នួន ជា ក៏បានបង្ហាញភស្តុតាងអោយឃើញផងដែរអំពីទំនាក់ទំនងដោយផ្ទាល់ជាមួយលោក Rob Lemkin, ដូចជាថា នៅពេលលោក Lemkin មានការព្រួយបារម្ភអំពីភាពត្រឹមត្រូវនៃភស្តុតាងដែលឋិតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទាក់

១២- លើសពីនេះ សហព្រះរាជអាជ្ញាបានសង្កេតឃើញថា មតិរបស់ ថេត សម្បត្តិ ដែលថា នួន ជា ត្រូវបានកាត់ក្តីឱ្យមានទោសដោយមិនត្រឹមត្រូវអំពីករណីទួលពោធិ៍ជ្រៃនោះ គឺដោយសារផ្អែកលើមូលដ្ឋានការយល់ច្រឡំអំពីមូលដ្ឋានច្បាប់ ដែលនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ លោក សម្បត្តិ មិនមែនជាមេធាវីនោះទេ មិនបានរៀនសូត្រអំពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះឡើយ ហើយហាក់ដូចជាមិនទាំងបានអានសាលក្រមទៀតផង។ លោក សម្បត្តិ បានពោលអះអាងថា នួន ជា ត្រូវបានចោទប្រកាន់ដោយខុសពីបទ "បញ្ជា" ឱ្យសម្លាប់នៅទួលពោធិ៍ជ្រៃ[24] ក៏ប៉ុន្តែឃើញហាក់ដូចជា មិនបានដឹងអំពីមូលដ្ឋានដែលសំខាន់ជាសារវន្តនៃពិរុទ្ធភាពរបស់ នួន ជា នោះគឺថាការសម្លាប់មនុស្សនៅទទួពោធិ៍ជ្រៃត្រូវបានបញ្ជា និងត្រួតមើលពីលើដោយលេខាភូមិភាគពាយ័ព្យឈ្មោះ រស់ ញឹម ដែលជាសហការីសមាជិកមួយរូបនៅក្នុងសហឧក្រិដ្ឋកម្មរួមនៃ បកក នោះឡើយ[25]។ ហេតុដូចនេះ សូម្បីតែបើសិនជា ភស្តុតាងជាដើមចមដែលកាន់កាប់ដោយ ថេត សម្បត្តិ និង Rob Lemkin បានបង្ហាញថាមានការជាប់ពាក់ព័ន្ធនឹង រស់ ញឹម និងកម្មាភិបាលនានានៃភូមិភាគពាយ័ព្យថាជាអ្នកទទួលខុសត្រូវចំពោះការសម្លាប់មនុស្ស នៅទួលពោធិ៍ជ្រៃក៏ដោយ ក៏ភស្តុតាងទាំងនោះនឹងគ្រាន់តែជួយពង្រឹងបន្ថែមដល់សាលក្រម របស់អង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ។

១៣- ចំណែកឯការជម្លៀសចេញពីទីក្រុងភ្នំពេញ ថេត សម្បត្តិ បានថ្លែងថា នួន ជា "បានទទួលស្គាល់ចំពោះពិរុទ្ធភាពរបស់គាត់ហើយ"[26] ទោះបីជាគាត់មិនបានបញ្ចេញឱ្យដឹងជាសាធារណៈ និងមិន

ទងនឹងទួលពោធិ៍ជ្រៃនោះ គាត់មិនបានខំស្វែងរកដើម្បីទាក់ទងជាមួយនឹងតុលាការអំពីសេចក្តីព្រួយបារម្ភណ៍ទាំងនោះឡើយ ប៉ុន្តែផ្ទុយទៅវិញបានផ្ញើអ៊ីម៉ែលទៅមេធាវីការពារក្តីរបស់ នួន ជា ដោយគាត់បានហៅ គោត្តនាមរបស់សហមេធាវី។ *សូមមេត្តាអាន* ឯកសារលេខ **E294** សំណើរបស់ នួន ជា សុំអោយទទួលយកភស្តុតាងថ្មីៗ អោយធ្វើការកោះហៅលោក Rob Lemkin និងផ្តួចផ្តើមគំនិតក្នុងការស៊ើបសួរ, ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣, កថាខណ្ឌទី២។

[24] ឯកសារលេខ **F2** សំណើសុំឱ្យទទួល និងចារណាលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង០០២/០១, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤, ទំព័រ ៥។

[25] ឯកសារលេខ **E313** សាលក្រមសំណុំរឿង០០២/០១, ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤, កថាខណ្ឌទី ៨៣៦ ("គណៈកម្មាធិការភូមិភាគពាយ័ព្យបានបញ្ជាអោយមានការប្រមូលផ្តុំ និងសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ។ រស់ ញឹម ដែលជាលេខាភូមិភាគពាយ័ព្យបានធ្វើជាអធិបតីនៅក្នុងអង្គប្រជុំមួយ ដែលបានចេញសេចក្តីណែនាំនេះ។ ... ហេតុដូចនេះ អង្គជំនុំជម្រះជឿជាក់ថា ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ អាចត្រូវបានដាក់ឱ្យអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមទទួលខុសត្រូវ យ៉ាងហោចណាស់ចំពោះ រស់ ញឹម ដែលជាអ្នកចូលរួមម្នាក់នៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ")។

[26] ឯកសារលេខ **F2** សំណើសុំឱ្យទទួល និងចារណាលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០១, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤, ទំព័រ ៦។

បានផ្តល់ភស្តុតាងរបស់គាត់ជូនតុលាការនូវខ្សែវីដេអូឬមួយក៏ឯកសារផ្សេងៗ ដែលក្នុងនោះមាន ថេតសំដី នួន ជា ក៏ដោយ។ ចំណែកឯឧក្រិដ្ឋកម្មផ្សេងៗទៀត លោក សម្បត្តិ បានបញ្ចេញយោបល់ថា នួន ជា "ត្រូវតែចាប់បង្ខំឱ្យទទួលខុសត្រូវ និងផ្តន្ទាទោស"[27]។ ការធ្វើបែបនេះ សូម្បីតែបើសិនជាយោបល់ទាំងឡាយរបស់ ថេត សម្បត្តិ ត្រូវបានទទួលយកហើយក៏ដោយក៏យោបល់ទាំងនោះនឹងមិនធ្វើឱ្យ នួន ជា រួចផុតពីការចោទប្រកាន់ដែរហើយ គឺជា "កត្តាកំណត់"ដែលនាំឱ្យឈាន ទៅដល់ការសម្រេចថាតើជនជាប់ចោទត្រូវមានទោស ឬ គ្មានទោស ដូចដែលលក្ខខណ្ឌបានតម្រូវនៅក្នុងវិធាន១០៨(៧)នៃវិធានផ្ទៃក្នុង។

*សំណើសុំឱ្យចេញដីកាកោះហៅ ថេត សម្បត្តិ និង Rob Lemkin*

១៤- ដូចដែលបានធ្វើការកត់សម្គាល់ខាងលើទាំងលោក ថេត សម្បត្តិ និងទាំងលោក Rob Lemkin បានបដិសេធជាដដែលៗក្នុងការធ្វើសហប្រតិបត្តិការជាមួយតុលាការ និងផ្តល់នូវច្បាប់ចម្លងនៃកំណាត់ហេតុធ្វើសម្ភាសន៍ជនជាប់ចោទ និងកម្មាភិបាល បកក ដទៃៗទៀត។ នៅក្នុងបទសម្ភាសន៍តាមរយៈវិទ្យុសម្លេងសហរដ្ឋអាមេរិករបស់លោក សម្បត្តិ កាលពីខែសីហា ឆ្នាំ២០១៤ គ្មានអ្វីទាល់តែសោះដែលបង្ហាញអោយដឹងថា ឥរិយាបថរបស់គាត់បានផ្លាស់ប្តូរ និងថាឥឡូវនេះគាត់មានបំណងចង់ផ្តល់សក្ខីកម្ម និងផ្តល់ភស្តុតាងរបស់គាត់ជូនតុលាការ។ សហព្រះរាជអាជ្ញាមានសង្ឃឹមយ៉ាងខ្លាំងថា លោក ថេត សម្បត្តិ នឹងសម្រេចចិត្តដើម្បីជួយដល់តុលាការនេះ និងធ្វើអោយមាននូវរបាយការណ៍ស្រាវជ្រាវរបស់គាត់ ដើម្បីអោយងាយរកបានដូចដែលមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក Stephen Heder, លោក David Chandler, លោក Philip Short, លោកស្រី Elizabeth Becker, លោក Henri Locard ហើយជាក់ស្តែងជនដទៃទៀតគ្រប់រូប និងគ្រប់អង្គការទាំងអស់ ដែលបានដឹកនាំធ្វើការសិក្សាស្រាវជ្រាវស្តីពីខ្មែរក្រហមធ្លាប់បានធ្វើរួចហើយកន្លងមក។ សហព្រះរាជអាជ្ញាប្រាកដក្នុងចិត្តថា ដូចគ្នានឹងករណីក្នុងការបញ្ចេញឯកសារខ្សែភាពយន្តដែលមានចំណងជើងថា *សត្រូវរបស់ប្រជាជន* (*Enemies of the People*) និងសៀវភៅដែលមានចំណងជើងថា *នៅខាងក្រោយវាលពិឃាត* (*Behind the Killing Fields*) ដែរ ភស្តុតាងបន្ថែមដែលកំពុងកាន់កាប់ ដោយ លោក សម្បត្តិ និង លោក Lemkin គឺនឹងមានលក្ខណៈដាក់បន្ទុកយ៉ាងខ្លាំង ។

---

[27] *ដូចខាងលើ*, ត្រង់ទំព័រ៤។

១៥- ដោយសារតែលក្ខណៈឆាប់ពេកមុនកំណត់នៃសំណើនានា សហព្រះរាជអាជ្ញាជូនជាយោបល់ថា អង្គជំនុំជម្រះតុលាការកំពូល គួរតែរង់ចាំមើលថាតើ ថេត សម្បត្តិ យល់ព្រមក្នុងការចូលមកបង្ហាញខ្លួន និងផ្តល់ភស្តុតាងនៅក្នុងដំណើរការនីតិវិធីជំនុំជម្រះក្តី ក្នុងសំណុំរឿងលេខ០០២/០២ ដែលត្រូវបានរំពឹងទុកថានឹងចាប់ផ្តើមនៅក្នុងពេលឆាប់ៗនេះដែរ ឬទេ នៅមុនពេលសម្រេចលើសំណើរបស់សហមេធាវីការពារក្តី ក្នុងការកោះហៅរូបគាត់មកធ្វើជាផ្នែកនៃសវនាការលើបណ្តឹងសាទុក្ខណាមួយនៅក្នុងសំណុំរឿងលេខ០០២/០១។ ទាំងសហព្រះរាជអាជ្ញា និងទាំងមេធាវីការពារក្តីរបស់ នួន ជា បានខំស្វែងរកនូវការចូលមកបង្ហាញខ្លួនរបស់គាត់ក្នុងនាមជាសាក្សីសវនាការមួយរូបនៅក្នុងសំណុំរឿងលេខ០០២។ ភស្តុតាងរបស់លោក សម្បត្តិ ស្ថិតនៅជាភស្តុតាងដែលមានការជាប់ទាក់ទងយ៉ាងខ្លាំងជាដដែល ទៅនឹងបញ្ហានានាដែលត្រូវធ្វើការកាត់សេចក្តីនៅក្នុងសវនាការជំនុំជម្រះក្តី ក្នុងសំណុំរឿងលេខ០០២/០២ ដែលក្នុងនោះរួមមាន៖ ការបោសសម្អាតផ្ទៃ ក្នុងនៃកម្មាភិបាល ប ក ក, ការធ្វើបាបពួកអតីតអ្នករដ្ឋការ និងទាហាននៃរបប លន់ នល់, និងតួនាទីរបស់ជនជាប់ចោទ[28]។ បើសិនជាលោក ថេត សម្បត្តិ ផ្តល់ជូននូវភស្តុតាងនៅក្នុងពេលជំនុំជម្រះក្តីដែលនឹងជិតមកដល់នោះ ជាបន្ទាប់មកទៀតភាគីនានាអាចនឹងដាក់ជូនអង្គជំនុំជម្រះនេះនូវភស្តុតាងដូចនេះណាមួយដែលពួកគេជឿថា ត្រូវបានធានាដោយវិធាន១០៨(៧) នៃវិធានផ្ទៃក្នុង។ មួយវិញទៀត បើសិនជាអង្គជំនុំជម្រះសាលាដំបូងមិនអាចមានលទ្ធភាពក្នុងការទទួលបាននូវភស្តុតាងពីលោក សម្បត្តិ ទេនោះ អង្គជំនុំជម្រះនេះអាចធ្វើការវាយតម្លៃថា តើនឹងមានការអនុញ្ញាតឱ្យនូវវិធានការណាជាបន្ថែមទៀតដែរ ឬទេ? ហើយដែលទំនងជានឹងទទួលបាននូវលទ្ធផលមួយផ្សេងពីនេះ។

១៦- ទាក់ទងនឹងសំណើសុំកោះហៅ Rob Lemkin សហព្រះរាជអាជ្ញាជូនជាសេចក្តីសន្និដ្ឋានថា សក្ខីកម្មរបស់គាត់មានគុណតម្លៃតិចតួច ឬគ្មានទាល់តែសោះចំពោះអង្គជំនុំជម្រះនេះ សម្រាប់ហេតុផលដដែល ដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនដែលមិនកោះហៅលោក Lemkin នៅក្នុងអំឡុងពេលសវនាការលើសំណុំរឿង០០២/០២[29]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថាគឺ ថេត សម្បត្តិ ទេដែល “បានដឹកនាំកិច្ចសម្ភាសន៍

[28] **E301/9/1** សេចក្តីសំរេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងវិសាភាពនៅក្នុងសំណុំរឿង០០២ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ៣៥ ៤២ ៤៤ ]។ ឯកសារលេខ **E315** សេចក្តីសំរេចស្តីពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២, ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤, កថាខណ្ឌទី១៤។

[29] **E294/1** សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី, ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក ROB LEMKIN, ២៤ កក្កដា ២០១៣, កថាខណ្ឌទី១៤-១៦។

ទាំងឡាយ” ដូច្នេះហើយ គឺ “ល្អបំផុតដែលត្រូវដាក់ជំនួស” ដើម្បីផ្តល់សក្ខីកម្មអំពីភស្តុតាងបែបដូច្នេះ[30]។ ផ្ទុយទៅវិញ លោក Lemkin មានការដឹងឮពីដំបូងដ៏តិចតួចដែលគាត់អាចផ្តល់ឱ្យបានក្នុងឋានៈជាសាក្សីអង្គហេតុ (ដោយសារគាត់ទើបតែបានចូលរួមក្នុងគម្រោងការរបស់ ថេត សម្បត្តិ នៅពេលជិតចប់ការស្រាវជ្រាវរបស់គាត់នៅឆ្នាំ២០០៦ប៉ុណ្ណោះ និងដោយសារគាត់មិនមានវត្តមាននៅក្នុងការសម្ភាសន៍ជាច្រើន ហើយមិននិយាយ និងមិនយល់ភាសាខ្មែរទៀតផង) ហើយគាត់ក៏មិនមាន “សម្បទាដែលត្រូវបានកំណត់សម្រាប់គុណវុឌ្ឍិជាអ្នកជំនាញ” ផងដែរ[31]។

### *សេចក្តីថ្លែងការណ៍ដោយចៅក្រម Cartwright នៅវិទ្យាស្ថាន Aspen*

១៧- មេធាវីការពារក្តីក៏បានស្វែងរកឱ្យមានការទទួលយកផងដែរ នូវសេចក្តីថ្លែងការណ៍ធ្វើឡើងដោយចៅក្រម Silvia Cartwright ខណៈដែលបានចូលរួមនៅក្នុងក្រុមប្រឹក្សាកិច្ចពិភាក្សាមួយ នៅវិទ្យាស្ថាន Aspen នៅខែវិច្ឆិកា ឆ្នាំ២០១៣[32]។

១៨- សហព្រះរាជអាជ្ញាបានសង្កេតពីដំបូងឃើញថា មេធាវីការពារក្តី នួន ជា ធ្លាប់បានទទួលយកនូវផ្នែកដ៏សំខាន់នានានៃសេចក្តីថ្លែងការណ៍របស់ចៅក្រម Cartwright ដែលចាំបាច់សម្រាប់ការយល់ដឹងពីបរិបទពិតប្រាកដ និងការចម្លងយកសេចក្តីថ្លែងការណ៍របស់គាត់។ ឧទាហរណ៍ ផ្នែកដំបូងចំនួនពីរដែលបានរំលងចោលដោយមេធាវីការពារក្តី[33] បង្ហាញឱ្យឃើញថា សេចក្តីថ្លែងការណ៍របស់គាត់ដែលថា “មិនមានរឿងបែបដូច្នេះណាមួយជាការជំនុំជម្រះក្តីដ៏ត្រឹមត្រូវទាំងស្រុងនោះទេ” គឺត្រូវបានធ្វើឡើងជាផ្នែកនៃការពិភាក្សាទូទៅ មួយអំពីមតិស្រប និងមតិផ្ទុយ ស្តីពីតុលាការកូនកាត់ ហើយថាចៅក្រម Cartwright បានកត់ សម្គាល់ថា បញ្ហាដូចគ្នានេះមាននៅតុលាការអន្តរជាតិដទៃទៀតដែរ (រួមមាន តុលាការ ICTY, រ៉្វាន់ដា និង សេរ៉ាឡេអូន) គឺមិនមានតុលាការ

[30] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី ១៤។

[31] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី ១៥។

[32] **E305/12.38R**។

[33] *សូមអាន* **F2/1** សំណើទីពីរស្នើសុំឱ្យពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១, ២ កញ្ញា ២០១៤, ទំព័រទី២ (រំលងចោលពីរកន្លែង ដែលមានដាក់សញ្ញា “[…]”)។

ណាមួយក្នុងចំណោមតុលាការទាំងនេះ "ជាគំរូដែល ល្អឥតខ្ចោះ" នោះទេ ហើយ "ទាំងអស់នោះ" គឺជា "ផលចេញមកពីបរិយាកាសនយោបាយ និងតុលាការ"[34]។

១៩- អំណះអំណាងរបស់មេធាវីការពារក្ដីដែលថា "យោងតាមចៅក្រម Cartwright ចៅក្រមកម្ពុជាគ្រហឹមដោយខឹងសម្បារទៅនឹងសក្ខីកម្មគាំទ្រ នួន ជា និងបញ្ចេញទឹកមុខ "យ៉ាងក្រៀមក្រំ" ទៅនឹងភស្ដុតាងដោះបន្ទុក"[35] គឺជាការចាត់លក្ខណៈមួយដែលមានការខុសឆ្គងយ៉ាងធំ ទៅលើសេចក្ដីថ្លែងការណ៍របស់គាត់។ បទអត្ថាធិប្បាយរបស់ចៅក្រម Cartwright គឺទាក់ទងនឹងផលប៉ះពាល់នៃភស្ដុតាងទៅលើផ្លូវចិត្តរបស់ចៅក្រមកម្ពុជាដែលធ្លាប់បានរស់នៅឆ្លងកាត់របបខ្មែរក្រហម, គឺមិនមែនអំពីភាពលំអៀងប្រឆាំងនឹងជនជាប់ចោទ[36] នោះទេ។ លើសពីនេះ គាត់បានធ្វើឱ្យការកត់ចំណាំទាំងនោះមានគុណវុឌ្ឍិ ដោយធ្វើការកត់សម្គាល់ថា គាត់មិន "យល់ពីអ្វីដែលពួកគាត់បាននិយាយទេ"[37] ដោយហេតុថាគាត់មិននិយាយភាសាខ្មែរទេ ដូច្នេះហើយបានជាវាច្បាស់ណាស់ដែលថាការបកស្រាយរបស់ចៅក្រម Cartwright ទៅលើទឹកមុខរបស់សហការីកម្ពុជារបស់គាត់គឺមានលក្ខណៈស្មានៗយ៉ាងធំធេង។

២០- ចៅក្រមទាំងអស់នាំយកមកជាមួយពួកគាត់នូវបទពិសោធន៍ និងមតិផ្ទាល់ខ្លួន ក៏ប៉ុន្តែក្នុងឋានៈជាអ្នកប្រកបវិជ្ជាជីវៈ គេបានហ្វឹកហ្វឺនពួកគាត់ឱ្យទុកបទពិសោធន៍ទាំងនោះមួយឡែក ហើយត្រូវធ្វើសេចក្ដីសម្រេចនានាដោយផ្អែកលើភស្ដុតាង និងច្បាប់។ មេធាវីការពារក្ដី នួន ជា គួរតែយល់រឿងនេះឱ្យបានច្បាស់លាស់ ជាពិសេស លោកមេធាវីជាតិ សុន អរុណ។ សូម្បីតែគាត់មានបទពិសោធន៍ផ្ទាល់ខ្លួនជាទាហាន លន់ នល់ ដែលបានរត់ទៅប្រទេសថៃ ដើម្បីគេចចេញពីការកាប់សម្លាប់នៅក្រោយខ្មែរក្រហមបានកាន់កាប់អំណាចនៅខែមេសា ឆ្នាំ១៩៧៥[38] ក៏ដោយ ក៏លោក

---

[34] ផ្នែកទីមួយដែលមេធាវីការពារក្ដីបានរំលងចោលទាំងស្រុងគឺមានដូចតទៅ៖ "ដូច្នេះ មិនមែនជាគំរូមួយដែលល្អឥតខ្ចោះនោះទេ ប៉ុន្តែខ្ញុំសូមលើកឡើងថាមិនមានតុលាការណាដែលគេបង្កើតឡើង ដូចជា រ្វាន់ដា យូហ្គោស្លាវី សេរ៉ាឡេអូន គឺជាគំរូដែលល្អឥតខ្ចោះនោះទេ។ តុលាការទាំងអស់នោះគឺជាផលចេញមកពីបរិយាកាសនយោបាយ និងតុលាការ"។

[35] **F2/1** សំណើទីពីរស្នើសុំឱ្យពិចារណាទៅលើភស្ដុតាងបន្ថែមទាក់ទងនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១, ២ កញ្ញា ២០១៤, ទំព័រទី១៤។

[36] *ដដែលដូចខាងលើ,* ត្រង់ទំព័រទី ៣-៤ ("មានលក្ខណៈងាយស្រួលច្រើនចំពោះខ្ញុំ និងចំពោះសហសេរិកអន្តរជាតិរបស់ខ្ញុំជាងសហសេវិកជាតិរបស់ខ្ញុំ ដែលពួកគាត់ទាំងអស់បានឆ្លងកាត់របបនេះ។ ...។ ដូច្នេះ បទពិសោធន៍របស់ពួកគាត់ ខ្ញុំមិនដឹងថាតើពួកគាត់អង្គុយស្ដាប់រហូតដល់បញ្ចប់បែបណានោះឡើយ។ ហើយការដែលខ្ញុំអាចស្ដាប់ឮពួកគាត់គ្រហឹម ពួកគាត់មិនប្រែទឹកមុខមាំរបស់ពួកគាត់ឡើយ...")។

[37] *ដដែលដូចខាងលើ,* ត្រង់ទំព័រទី ៣ ("ខ្ញុំមិនយល់ពីអ្វីដែលពួកគាត់បាននិយាយទេ ប៉ុន្តែខ្ញុំគិតស្មានវា")។

[38] បទសម្ភាសន៍មួយជាមួយនឹងលោក សុន អរុណ ដែលមានចំណងជើងថា "Devil's Advocates" ដែលបានបោះពុម្ពផ្សាយនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ នៅក្នុងទស្សនាវដ្ដី Diplomat និយាយថា៖ "នៅដើមឆ្នាំ១៩៧០ លោក អរុណ បានបំរើនៅក្នុងកងទ័ពកម្ពុជាដែលគាំទ្រ

សុន អរុណ បានការពារកូនក្ដីរបស់គាត់នៅក្នុងការជំនុំជម្រះក្ដីយ៉ាងស្វាហាប់ និងជាផ្នែកមួយនៃក្រុមមេធាវីការពារក្ដីដែលប្រកបទៅដោយវិជ្ជាជីវៈ ដែលបានជំទាស់ទៅនឹងគ្រប់ភស្តុតាងទាំងអស់ដែលទាក់ទងនឹងការដោតគោលដៅរបស់ បកក ទៅលើអតីតពួកអ្នករដ្ឋការ និងពួកទាហាននៃរបបសាធារណរដ្ឋខ្មែរ។ មេធាវីការពារក្ដីមិនអាចអះអាងឲ្យជឿជាក់បានទេថា ពួកចៅក្រមកម្ពុជាគឺមិនមានសមត្ថភាពអាចធ្វើការវិនិច្ឆ័យលើសំណុំរឿងនេះឲ្យបានត្រឹមត្រូវ និងអនុលោមទៅតាមច្បាប់ និងភស្តុតាងបានទេ ពីព្រោះពួកនោះគឺគ្រាន់តែមានបទពិសោធន៍ផ្ទាល់ខ្លួនមកពីរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ។

២១- សំខាន់បំផុត គឺពុំមានអ្វីទាល់តែសោះនៅក្នុងការកត់ចំណាំរបស់ចៅក្រម Cartwright ដែលលើកឡើងថា សេចក្ដីសម្រេចណាមួយក៏ដោយរបស់អង្គជំនុំជម្រះសាលាដំបូង គឺត្រូវបានប៉ះពាល់ដោយបទពិសោធន៍ផ្ទាល់ខ្លួន ភាពលំអៀង ឬឥទ្ធិពលនយោបាយទេ។ ផ្ទុយទៅវិញ នៅក្នុងផ្នែកសំខាន់មួយផ្សេងទៀតនៃសេចក្ដីថ្លែងការណ៍របស់គាត់ដែលមេធាវីការពារក្ដីបានរំលងចោល ចៅក្រម Cartwright បានពិភាក្សាអំពីរបៀបដែលចៅក្រមជាតិ និងអន្តរជាតិ "ធ្វើការជាមួយគ្នា" នៅ អង្គជំនុំជម្រះបានយ៉ាងល្អ ហើយបានទទួលជោគជ័យនៅក្នុងការឈាន ដល់នូវសេចក្ដីសម្រេចនានាដែលមានសម្អាងហេតុ[39]។ គាត់ក៏បានថ្លែងយ៉ាងច្បាស់លាស់ផងដែរ ថាចៅក្រមគឺ "មិនបានទទួលឥទ្ធិពល" ដោយយោបល់នានាស្ដីពីអង្គជំនុំជម្រះ ដែលបានធ្វើឡើងដោយមេដឹកនាំនយោបាយនោះទេ[40]។

២២- សហព្រះរាជអាជ្ញាជូនជាសេចក្ដីសន្និដ្ឋានថា ការរអ៊ូរទាំ ឬភាពស្រងូតស្រងាត់ម្ដងម្កាលនៅលើផ្ទៃមុខរបស់ចៅក្រមណាម្នាក់ គឺមិនមែនជាមូលដ្ឋាននៃបណ្ដឹងសាទុក្ខដែលគួរឲ្យសរសើរនោះទេ

ដោយ ស.រ.អា ក្នុងឋានៈជាវរសេនីយ៍ត្រី បញ្ជាលើកងវរសេនាតូចមួយដែលមានមនុស្សជាងប្រាំរយនាក់នៅក្នុងសង្គ្រាមដ៏បរាជ័យមួយប្រឆាំងនឹងពួកកុម្មុយនីស ប៉ុល ពត...។ មិនយូរប៉ុន្មានក្រោយពេលពួកខ្មែរក្រហមកាន់កាប់ទីក្រុងនៅ ខែមេសា ឆ្នាំ១៩៧៥ លោក អរុណ បានរត់ទៅប្រទេសថៃ។ គាត់និយាយថា បើគាត់នៅស្រុកខ្មែរ គាត់ប្រាកដជាត្រូវគេសម្លាប់ជាមិនខាន"។

[39] ផ្នែកទីពីរនៃការកត់ចំណាំរបស់ចៅក្រម Cartwright ដែលមេធាវីការពារក្ដីបានរំលងចោល ពីក្នុងឯកសារលេខ **E305/12.38R** រួមមានសេចក្ដីថ្លែងដូចតទៅនេះ៖"អង្គហេតុពិតដែលថាយើងមានសម្អាងហេតុនៅក្នុងសេចក្ដីសម្រេចរបស់យើងគឺជាគំរូមួយល្អណាស់សម្រាប់ប្រព័ន្ធយុត្តិធម៌ក្នុងស្រុក ហើយខ្ញុំសប្បាយចិត្តណាស់ដោយថ្មីៗនេះបានឮថាខ្លះពិតជាបានចាប់ផ្ដើមផ្ដល់សម្អាងហេតុនៅក្នុងសេចក្ដីសម្រេចនានារបស់ពួកគេ ដែលជាការមួយជំរុញទឹកចិត្តយ៉ាងខ្លាំង។ យើងធ្វើការជាមួយគ្នាបានយ៉ាងល្អនៅតាមអង្គជំនុំជម្រះនានា រវាងចៅក្រមកម្ពុជា និងអន្តរជាតិ ហើយខ្ញុំគិតថារឿងនោះមានលទ្ធផលចេញមកល្អ។ លោកប្រធានធ្លាប់បាននិយាយជាមួយខ្ញុំជាច្រើនដងអំពីមេរៀនទាំងឡាយ ដែលគាត់ចង់យកតាមរបៀបដែលពួកយើងចាត់ចែងការងារនេះ យកត្រឡប់ទៅប្រើនៅក្នុងប្រព័ន្ធយុត្តិធម៌ក្នុងស្រុក"។

[40] **F2/1** សំណើទីពីរស្នើសុំឲ្យពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១, ២ កញ្ញា ២០១៤, ទំព័រទី៣។

ហើយច្បាស់ណាស់ វាមិនមែនជាភស្តុតាងដែលអាចជា "កត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេច" មួយនៅក្រោមវិធាន ១០៨(៧) និងជាទឡ្ហីករណ៍ដែលផ្លាស់ប្តូរដល់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមួយដែលមានសំអាងហេតុ បាននោះទេ។

## *សៀវភៅរបស់ Marcel Lemonde*

២៣- ចុងបញ្ចប់ ទាក់ទងនឹងសំណើរបស់មេធាវីការពារក្តីដែលស្នើសុំឱ្យទទួលយកសៀវភៅ *Un Juge face aux Khmer Rouges* របស់លោក Marcel Lemonde សហព្រះរាជអាជ្ញាសង្កេតឃើញថា សៀវភៅនេះមិនបង្កើតបានជា "ភស្តុតាងថ្មី" ដែលត្រូវស្ថិតនៅក្រោមវិធាន១០៤ និង១០៨(៧) ស្តីពីការទទួលយកភស្តុតាងនោះទេ។ ផ្ទុយទៅវិញ នេះគឺជាភស្តុតាងដែលមេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឱ្យទទួលយក នៅក្នុងអំឡុងពេលសវនាការ ក៏ប៉ុន្តែត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង[41]។ ដូច្នេះហើយ នីតិវិធីត្រឹមត្រូវសម្រាប់មេធាវីការពារក្តី គឺមិនត្រូវដាក់ញត្តិតាមវិធាន១០៨(៧) ទេ ដែលវិធាននេះអនុវត្តតែចំពោះភស្តុតាងណាដែល "មិនអាចរកបានក្នុងពេលសវនាការ" ប៉ុណ្ណោះ តែផ្ទុយទៅវិញទេ គឺត្រូវលើកឡើងពីបញ្ហានានាទាក់ទងនឹងភាពអាចទទួលបាន និងពីទម្ងន់នៃភស្តុតាងនេះ ធ្វើជាផ្នែកនៃបណ្តឹងសាទុក្ខរបស់ខ្លួន។

២៤- ការពឹងផ្អែករបស់មេធាវីការពារក្តីទៅលើភាពខ្វះចន្លោះ ដែលបានលើកឡើងនៅក្នុងអំឡុងពេលនៃដំណាក់ការស៊ើបសួរនៃសំណុំរឿង០០២ ក៏ទំនងជាត្រូវបានរារាំងដោយវិធាន៧៦(៧) ផងដែរ ដែលចែងថា "ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ" ហើយថា "គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ"។ មេធាវីការពារក្តីមានលទ្ធភាពអាចលើកឡើងនូវបញ្ហានានាពាក់ព័ន្ធនឹងកិច្ចស៊ើបសួរបាន នៅមុនបណ្តឹងឧទ្ធរណ៍របស់ខ្លួនដាក់ជូនទៅអង្គបុរេជំនុំជម្រះ។ សាលក្រមលើសំណុំរឿង០០២/០១ ត្រូវបានចេញដោយអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីរយៈពេលជិតពីរឆ្នាំនៃការស្តាប់ភស្តុតាង ហើយបើមេធាវីការពារក្តីមានបំណងប្តឹងសាទុក្ខលើសាលក្រមនោះៗ បញ្ហាដែលពាក់ព័ន្ធគឺ ភាពត្រឹមត្រូវនៃ

---

[41] **E280/2** សំណើសុំបន្ថែម សុំដាក់បញ្ចូលអត្ថបទដកស្រង់ចេញពីសៀវភៅ លោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល, ៨ ឧសភា ២០១៣។ **E280/2/1** សេចក្តីសម្រេចលើសំណើសុំលើកទីពីររបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកអត្ថបទដកស្រង់ចេញពីសៀវភៅរបស់អតីតសហចៅក្រមស៊ើបអង្កេត LEMONDE, ១៣ សីហា ២០១៣។

កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី តែមិនមែនជាភាពមិនប្រក្រតីដែលបានលើកឡើងនៅក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបសួរនោះទេ។

## III. ដំណោះស្រាយដែលស្នើសុំ

២៥- ចំពោះមូលហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល៖

១. បដិសេធសំណើសុំឲ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែម ដោយចាត់ទុកថាវាឆាប់ពេក,

២. ផ្តល់សេចក្តីណែនាំដល់ភាគីនានា អំពីពេលវេលាសមស្រប ក្នុងការដាក់សំណើសម្រាប់ភស្តុតាងបន្ថែម អនុលោមតាមវិធាន១០៨(៧), និង

៣. អនុញ្ញាតឲ្យសហព្រះរាជអាជ្ញាធ្វើការឆ្លើយតបទាំងស្រុងទៅនឹងសំណើបែបនេះ បន្ទាប់ពីមេធាវីការពារក្តីបានដាក់ការជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN** សហព្រះរាជអាជ្ញា | | |